**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ៣៦ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការរៀបចំ និងការប្រព្រឹត្តិទៅ នៃលេខាធិការដ្ឋានក្រុមការងារ ថ្នាក់ជាតិចុះមូលដ្ឋាន រាជធានី ខេត្ត ដើម្បីត្រួតពិនិត្យ និងគាំទ្រ ការអនុវត្ត កម្មវិធីនយោបាយ និង យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាលកម្ពុជា

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី ០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខនស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែ មិថុនា ឆ្នាំ២០១៨ ដែលប្រកាសឲ្យ ប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខនស/រកម/០១៩៦/០៨ ចុះថ្ងៃ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែ សីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងមហាផ្ទៃ
- យោងកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាល សម្រាប់នីតិកាលទី៦ នៃរដ្ឋសភា
- យោងតាមសំណើរបស់ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

**សម្រេច**

## ជំពូក ទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

ត្រូវបានបង្កើតលេខាធិការដ្ឋានក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋាន ដើម្បីធ្វើជាសេនាធិការឲ្យរាជរដ្ឋាភិបាល លើសកម្មភាពក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋានរាជធានី ខេត្ត ដើម្បីត្រួតពិនិត្យ និងគាំទ្រការអនុវត្ត កម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤របស់រាជរដ្ឋាភិបាល ដែលហៅកាត់ថា "លេខាធិការដ្ឋាន ក.ជ.ម."។

**មាត្រា២ .-**

លេខាធិការដ្ឋាន ក.ជ.ម. មានទីតាំងស្ថិតនៅក្នុងទីស្តីការក្រសួងមហាផ្ទៃ។

## ជំពូក ទី២
## តួនាទី ភារកិច្ច

**មាត្រា៣ .-**

លេខាធិការដ្ឋាន ក.ជ.ម. មានតួនាទីធ្វើជាសេនាធិការជូនរាជរដ្ឋាភិបាល ក្នុងការសម្របសម្រួល បូកសរុបរាយការណ៍អំពីសកម្មភាពរបស់ ក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋានរាជធានី ខេត្ត ដើម្បីត្រួតពិនិត្យ និងគាំទ្រការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាល។

**មាត្រា៤ .-**

លេខាធិការដ្ឋាន ក.ជ.ម. មានភារកិច្ចសំខាន់ៗដូចខាងក្រោម៖

- រៀបចំសេចក្តីព្រាងសមាសភាពក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋានរាជធានី ខេត្ត ដាក់ជូនសម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ដើម្បីពិនិត្យមុននឹងដាក់ជូនប្រមុខរាជរដ្ឋាភិបាល ពិនិត្យសម្រេច។
- សម្របសម្រួលការងារប្រចាំថ្ងៃរបស់ ក.ជ.ម. ស្របតាមការកំណត់ និងការសម្រេច របស់រាជរដ្ឋាភិបាល
- ទទួលរបាយការណ៍ពីក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋានរាជធានី ខេត្ត ដើម្បីបូកសរុបធ្វើរបាយការណ៍ឲ្យបានទៀងទាត់ ជូនរាជរដ្ឋាភិបាល។
- ធ្វើការបូកសរុបវាយតម្លៃអំពីលទ្ធផលការងារ និង បញ្ហាប្រឈមរបស់ក្រុមការងារថ្នាក់ ជាតិចុះមូលដ្ឋានរាជធានី ខេត្ត ប្រចាំត្រីមាស ឆមាស និងប្រចាំឆ្នាំ ដើម្បីដាក់ជូនរាជរដ្ឋាភិបាល។
- សហការសម្របសម្រួល ជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ និងរដ្ឋបាល រាជធានី ខេត្ត ដើម្បីរៀបចំកិច្ចប្រជុំបូកសរុបប្រចាំឆ្នាំរបស់ក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋានរាជធានី ខេត្ត។
- បំពេញការងារផ្សេងៗទៀត តាមការចាំបាច់របស់រាជរដ្ឋាភិបាល និងតាមការណែនាំដោយផ្ទាល់ពី សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

## ជំពូក ទី៣
## រចនាសម្ព័ន្ធ

**មាត្រា៥ .-**

លេខាធិការដ្ឋាន ក.ជ.ម. ត្រូវដឹកនាំដោយប្រធាន១រូប អមដោយអនុប្រធានចំនួន០៣រូបជាជំនួយការ។

ប្រធានលេខាធិការដ្ឋាន គឺជារដ្ឋលេខាធិការ ០១រូប របស់ក្រសួងមហាផ្ទៃ។

អនុប្រធានលេខាធិការដ្ឋាន មានឋានៈស្មើ អនុរដ្ឋលេខាធិការ។

ប្រធាន អនុប្រធានលេខាធិការដ្ឋានក.ជ.ម. ត្រូវតែងតាំងដោយព្រះរាជក្រឹត្យ តាមសំណើរបស់នាយករដ្ឋមន្ត្រី តាមការស្នើសុំពីសម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

**មាត្រា៦ .-**

លេខាធិការដ្ឋាន ក.ជ.ម. មានសិទ្ធប្រើប្រាស់ត្រា របស់ក្រសួងមហាផ្ទៃ។

**មាត្រា៧ .-**

លេខាធិការដ្ឋាន ក.ជ.ម. មានអង្គភាពចំណុះ ដូចខាងក្រោម៖

-អង្គភាពរដ្ឋបាល

-អង្គភាពតាមដានវាយតម្លៃ និងផ្សព្វផ្សាយ។

**មាត្រា៨ .-**

អង្គភាពនីមួយៗ ត្រូវដឹកនាំដោយប្រធាន០១រូបនិងអនុប្រធានចំនួន០៣រូប ព្រមទាំង

មានមន្ត្រីមួយចំនួនជាជំនួយការ។

ប្រធានអង្គភាពមានឋានៈស្មើអគ្គនាយករង អនុប្រធានអង្គភាពមានឋានៈស្មើប្រធាននាយកដ្ឋាន និងត្រូវតែងតាំងដោយអនុក្រឹត្យ តាមសេចក្តីស្នើសុំពីសម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

**មាត្រា៩ .-**

ប្រធាន អនុប្រធាន អង្គភាព និងមន្ត្រីបុគ្គលិក ដែលបម្រើការងារក្នុងអង្គភាពចំណុះត្រូវជ្រើសរើសពីក្នុងចំណោមមន្ត្រី នៃក្រសួងមហាផ្ទៃ និងក្រសួង ស្ថាប័ននានាតាមការចាំបាច់។

## ជំពូក ទី៤
## របៀបរបបការងារ

**មាត្រា១០ .-**

ប្រធានលេខាធិការដ្ឋាន ក.ជ.ម. ត្រូវរាយការណ៍ និងស្នើសុំយោបល់ពីសម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ក្នុងការសម្របសម្រួលការងារជាមួយគ្រប់ក្រសួង ស្ថាប័ននានា និងរដ្ឋបាលថ្នាក់ក្រោមជាតិ។

**មាត្រា១១ .-**

លេខាធិការដ្ឋានក.ជ.ម. ត្រូវសហការសម្របសម្រួលជាមួយ ក្រសួង ស្ថាប័ននានា ដើម្បីគាំទ្រដល់កិច្ចដំណើរការប្រចាំថ្ងៃរបស់លេខាធិការដ្ឋាន។

**មាត្រា១២ .-**

ប្រធានលេខាធិការដ្ឋាន ក.ជ.ម. គឺជាប្រធានបុគ្គលិកទាំងអស់របស់លេខាធិការដ្ឋាន រួមទាំងអនុប្រធានលេខាធិការដ្ឋាន ប្រធាន អនុប្រធានអង្គភាពចំណុះលេខាធិការដ្ឋានផង។

**មាត្រា១៣ .-**

អនុប្រធានលេខាធិការដ្ឋានក.ជ.ម. ត្រូវបំពេញការងារតាមការចាត់ចែងរបស់ប្រធានលេខាធិការដ្ឋានហើយត្រូវមានការទទួលខុសត្រូវ និងគណនេយ្យភាពចំពោះប្រធានលេខាធិការដ្ឋាន និងអាចជំនួសប្រធានលេខាធិការដ្ឋាន តាមឋានានុក្រម ក្នុងពេលប្រធានលេខាធិការដ្ឋានអវត្តមាន។

**មាត្រា១៤ .-**

ប្រធានអង្គភាពនីមួយៗ ត្រូវមានការទទួលខុសត្រូវអំពីកិច្ចការរបស់ខ្លួន និងមានគណនេយ្យភាពចំពោះប្រធានលេខាធិការដ្ឋាន។

**មាត្រា១៥ .-**

មន្ត្រីរាជការ ដែលបម្រើការងារក្នុង អង្គភាពចំណុះលេខាធិការដ្ឋាន ក.ជ.ម. ត្រូវមានការទទួលខុសត្រូវអំពីកិច្ចការរបស់ខ្លួន និងមានគណនេយ្យភាពដោយផ្ទាល់ចំពោះប្រធានអង្គភាពរបស់ខ្លួន និងត្រូវមានការទទួលខុសត្រូវ និងគណនេយ្យភាពតាមឋានានុក្រម ចំពោះប្រធានលេខាធិការដ្ឋាន។

## ជំពូក ទី៥
## អំពីថវិកា

**មាត្រា១៦.-**

កញ្ចប់ថវិការបស់លេខាធិការដ្ឋាន ក.ជ.ម. មានក្នុងកញ្ចប់ថវិកាដោយឡែករបស់ខ្លួនក្នុងក្រសួងមហាផ្ទៃ។

## ជំពូក ទី៦
## អវសានប្បញ្ញត្តិ

**មាត្រា១៧ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយ នឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា១៨ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការ គណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័ន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ពុធ ១ កើត ខែ ផល្គុន ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី ៦ ខែ មីនា ឆ្នាំ២០១៩

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោ
នាយករដ្ឋមន្ត្រី សូមចុះហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**សម្តេចក្រឡាហោម ស ខេង**

<u>**កន្លែងទទួល:**</u>

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ១៨*
- *រាជកិច្ច*
- *ឯកសារ កាលប្បវត្តិ*